**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា–ឥណ្ឌា

≈≈≈≈≈≈≈≈

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ស ម្រេ ច

**មាត្រា ១:** ត្រូវបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលមួយ ដែលមានឈ្មោះថា **មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា** (Cambodia-India Entrepreneurship Development Center) ហៅកាត់ថា "**ម អ ស ក ឥ**" **(CIEDC)**។ មជ្ឈមណ្ឌលនេះ មានឋានៈស្មើនាយកដ្ឋាន ហើយស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ២:** មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា មានភារកិច្ច :

- បណ្តុះបណ្តាលផ្នែកសហគ្រិនគ្រប់កម្រិត រួមមាន វគ្គខ្លី បឋម មធ្យម និងឧត្តម
- បណ្តុះបណ្តាលគ្រូផ្នែកសហគ្រិន
- ផ្តល់សេវាពិគ្រោះយោបល់ក្នុងការធ្វើជំនួញ
- ស្រាវជ្រាវ និងរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលសហគ្រិន

- ជួយគាំទ្រដល់សិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សានៅ **ម អ ស ក ឥ** ដើម្បីអភិវឌ្ឍសហគ្រាស
- ផ្តល់ចំណេះដឹង ចំណេះធ្វើ និងបច្ចេកទេសដល់សហគ្រិនថ្មីនៅក្នុងការបង្កើតសហគ្រាសថ្មី
- ផ្តល់ការបណ្តុះបណ្តាលផ្នែកភាសាអង់គ្លេស និងផ្នែកព័ត៌មានវិទ្យា
- ទំនាក់ទំនងជាមួយវិទ្យាស្ថានក្នុង និងក្រៅប្រទេស អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ក្រសួង-ស្ថាប័ន និងក្រុមហ៊ុននានា ដើម្បីធ្វើឱ្យការបណ្តុះបណ្តាលផ្នែកសហគ្រិនកាន់តែមានគុណភាព និងមានប្រសិទ្ធភាពសមស្របទៅនឹងការរីកចម្រើនរបស់ទីផ្សារក្នុង និងក្រៅប្រទេស ។

**មាត្រា ៣:** មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា ដឹកនាំដោយនាយកមួយរូប និងមាននាយករងមួយចំនួន តាមការចាំបាច់ ។

**មាត្រា ៤:** ចំពោះមុខនេះមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌាមានការិយាល័យចំនួនប្រាំ :

១- ការិយាល័យរដ្ឋបាល

២- ការិយាលយ័ហិរញ្ញវត្ថុ

៣- ការិយាល័យបណ្តុះបណ្តាល

៤- ការិយាល័យទំនាក់ទំនង និងពិគ្រោះការផ្នែកសហគ្រិន

៥- ការិយាល័យផែនការ

ទៅអនាគត មជ្ឈមណ្ឌលអាចនឹងបើកការិយាល័យមួយចំនួនទៀត តាមសំណូមពរភារកិច្ចជាក់ស្តែង ។

**មាត្រា ៥:** មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា កាន់កាប់ និងប្រើប្រាស់គណនេយ្យ តាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិសម្រាប់ដំណើរការមជ្ឈមណ្ឌល និងមានខ្ទង់គណនេយ្យដោយឡែក ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៦*

**ញឹប ប៊ុនឆិន**

***ចម្លងជូន :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦ "ដើម្បីអនុវត្ត*
- *ឯកសារ-កាលប្បវត្តិ*